Fact sheet

# Recovery of unused water licence entitlements
# ការដកហូតយកសិទ្ធកាន់កាប់អាជ្ញាប័ណ្ណបូមទឹកដែលមិនបានប្រើ

នៅដែនដីភាគខាងជើង (NT) មានទឹកតែមួយចំណែកតូចទេនៃស្ទឹងទន្លេបឹងបួ ឬល្អាងទឹកក្រោមដី ដែលគេអាចយកទៅប្រើប្រាស់ក្នុងផ្លូវសេដ្ឋកិច្ចបាន។

ធនធានទឹកភាគច្រើនគឺបិតនៅក្នុងប្រព័ន្ធដើម្បីទ្រទ្រង់បរិស្ថាន និងវប្បធម៌។

ធនធានទឹកផ្តល់ជូនតាមរយៈអាជ្ញាប័ណ្ណបូមទឹក តែបែរជាមិនបានបូមយកទៅប្រើប្រាស់ឡើយ ដូច្នេះ ធនធានទឹកនេះគួរត្រូវបានប្រើប្រាស់ពីសំណាក់មនុស្សផ្សេងទៀត។

ការបែងចែកធនធានទឹកមើលទៅហាក់បីដូចជាបានបំពេញគ្រប់គ្រាន់ពេញលេញអស់ហើយ នៅខណៈដែលអ្នកមានអាជ្ញាប័ណ្ណជាច្រើនពុំបានប្រើប្រាស់ធនធានទឹកឡើយ ដែលអាចធ្វើឱ្យរាំងស្ទះដល់ការផ្តល់អាជ្ញាប័ណ្ណដល់ការដាក់ពាក្យសុំថ្មីៗទៀត។ ផ្អែកតាមគោលនយោបាយ ការដកហូតសិទ្ធប្រើប្រាស់ទឹកគឺជាអ្វីដែលត្រូវធ្វើ នៅគ្រាដែលពុំមានការប្រើប្រាស់ធនធានទឹកជាប់លាប់ទេនោះ។

ការដកហូតសិទ្ធកាន់កាប់អាជ្ញាប័ណ្ណដែលមិនបានយកទៅប្រើប្រាស់ គប្បីធ្វើឡើងដើម្បីធានានូវការប្រើធនធានទឹកតាមលទ្ធភាពយ៉ាងពេញលេញសម្រាប់ផលប្រយោជន៍នៃពលរដ្ឋរស់នៅក្នុងដែនដីភាគខាងជើង។

នៅតាមតំបន់នានាដែលមានការបែងចែកធនធានទឹកលើសហួសប្រមាណនោះ ទឹកដែលដកហូតយកមកវិញនឹងបង្វិលទៅឱ្យបរិស្ថាន ដើម្បីជួយរក្សាតុល្យភាពធនធាន ក្នុងទិសដៅឆ្ពោះទៅរកការគ្រប់គ្រងធនធាននោះឱ្យមាននិរន្តរភាព។

នៅតំបន់នានាដទៃទៀត ធនធានទឹកដែលដកហូតមកវិញនឹងបង្វែរជូនសម្រាប់ការប្រើប្រាស់របស់ពលរដ្ឋឯទៀត។

## តើការដកហូតយកធនធានទឹកនេះធ្វើឡើងដោយរបៀបណា

| | |
|---|---|
| ជំហានទី1. | ក្រសួងធ្វើការប្រៀបធៀបបរិមាណ(វ៉ូលូម) ទឹកដែលមានបញ្ជាក់នៅលើអាជ្ញាប័ណ្ណនីមួយៗ (សិទ្ធប្រើប្រាស់ទឹកតាមរយៈអាជ្ញាប័ណ្ណដែលផ្តល់ឱ្យ)ទៅនឹងការប្រើប្រាស់ទឹកដែលបានរាយការណ៍ជាក់ស្តែង។<br><br>នៅពេលដែលការប្រើប្រាស់ធនធានទឹកជាក់ស្តែងមានបរិមាណតិចមែនទែននៅក្រោមកម្រិតសិទ្ធប្រើប្រាស់ទឹកតាមរយៈអាជ្ញាប័ណ្ណដែលផ្តល់ឱ្យ សម្រាប់រយៈពេល៣ឆ្នាំជាប់ៗគ្នាឬក៏យូរជាងពេល៣ឆ្នាំ អាជ្ញាធរអាចដកហូតយកទឹកពីអាជ្ញាប័ណ្ណនោះ។ |
| ជំហានទី2. | ក្រសួងនឹងផ្តល់ដំណឹងទៅអ្នកកាន់កាប់អាជ្ញាប័ណ្ណដើម្បីជម្រាបថា អាជ្ញាធរកំពុងតែធ្វើការពិចារណាទៅលើការដកហូតយកអាជ្ញាប័ណ្ណនោះ។ ក្រសួងនឹងផ្តល់ឱកាសឱ្យអ្នកកាន់កាប់អាជ្ញាប័ណ្ណធ្វើការឆ្លើយតប។ |



NORTHERN TERRITORY GOVERNMENT

| | |
|---|---|
| **ជំហានទី3.** | អ្នកកាន់កាប់អាជ្ញាប័ណ្ណអាចឆ្លើយតបទៅក្រសួងវិញ ដើម្បីពន្យល់បង្ហាញពីតម្រូវការទឹកពិតជាក់ស្តែង ដោយផ្តល់នូវព័ត៌មានឬឯកសារអមដើម្បីគាំទ្រការបកស្រាយពន្យល់នោះ។ |
| **ជំហានទី4** | អធិការគ្រប់គ្រងធនធានទឹក នឹងធ្វើការពិចារណារាល់ព័ត៌មានពាក់ព័ន្ធទាំងអស់ ហើយធ្វើការសម្រេចចិត្តអំពីសិទ្ធកាន់កាប់អាជ្ញាប័ណ្ណដែលមិនបានប្រើ។អធិការនឹងសរសេរលិខិតទៅជូនអ្នកកាន់កាប់អាជ្ញាប័ណ្ណ ដើម្បីផ្តល់ដំណឹងអំពីការសម្រេចចិត្តនេះ។ អ្នកាន់កាប់អាជ្ញាប័ណ្ណមានសិទ្ធស្នើសុំឱ្យមានការពិនិត្យលើសេចក្តីសម្រេចចិត្តនេះសាឡើងវិញ។ |

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងមកយើងខ្ញុំតាម water.regulation@nt.gov.au ឬទូរសព្ទលេខ 08 8999 4455។